សារព័ត៌មាន
# ខ្មែរម្ចាស់ស្រុក
Khmer Machas Srok News

សារព័ត៌មានចេញផ្សាយប្រចាំថ្ងៃ
ឆ្នាំទី ០២ លេខ ២៤០ ចេញផ្សាយថ្ងៃ ពុធ ទី ១០ ខែ កញ្ញា ឆ្នាំ ២០០៨

# ព្រះមហាក្សត្រត្រាស់បង្គាប់ឱ្យសមាជិកសភាគណបក្សសមរង្ស៊ីទាំង២៦រូបចូលប្រជុំថ្ងៃដំបូង

## អ៊ឹម សួស្តី ប្រកាសទទួលស្គាល់អ្នកតំណាងរាស្ត្រថ្មីរបស់គណបក្សសមរង្ស៊ីទាំង២៦រូបជាផ្លូវការហើយ


ព្រះករុណាសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រខ្មែរ


លោក សម រង្ស៊ី អ្នកតំណាងរាស្ត្រមណ្ឌលកំពង់ចាម


លោក អេង ឆៃអ៊ាង អ្នកតំណាងរាស្ត្រមណ្ឌលបាត់ដំបង


លោកស្រី មូ សុខហួរ អ្នកតំណាងរាស្ត្រមណ្ឌលកំពត

ដោយ : ស្បាទរីយ៍

ព្រះមហាក្សត្រ ព្រះបរមនាថ *នរោត្តម សីហមុនី* បាន ត្រាស់បង្គាប់ សមាជិកសភាថ្មីនៃគណបក្សសមរង្ស៊ី ទាំង២៦ រូបឱ្យចូលរួមប្រជុំ នៅថ្ងៃដំបូង ដែលគ្រោងនឹងធ្វើនៅថ្ងៃទី២៤ ខែកញ្ញា ២០០៨ នៅវិមានរដ្ឋសភា ។ ប៉ុន្តែលោក*សម រង្ស៊ី* ប្រធានគណបក្សសម រង្ស៊ី និង លោក*កឹម សុខា* ប្រធានគណ

តទៅទំព័រ៤ ម

# ពូថាឡាវឈ្លានពានចូលដីខ្មែរអស់ជាង៤គីឡូម៉ែត្រ

ដោយ : រតនៈ

រយៈពេល ជាងមួយខែនេះ ទាហានឈុតខ្មៅសៀម បានឈ្លានពាន ចូលបូរណភាពទឹកដីខ្មែរជាច្រើនកន្លែង នៅតំបន់ក្បែរប្រាសាទព្រះវិហារ តំបន់ខ្លះនៅស្រុកអន្លង់វែង, នៅប្រាសាទតាមាន់ធំ និងនៅភូមិជប់

តទៅទំព័រ៤ គ


លោក ម៉ៅ មុនីវណ្ណ អ្នកតំណាងរាស្ត្រមណ្ឌលកំពង់ចាម

# មានក្រុមនៅក្នុងខ្សែមានខ្សែនៅក្នុងបក្ខពួកនិងមានបក្ខពួកនៅក្នុងគណបក្សប្រជាជន


លោក ខឹម គីមស៊ា


នាយឧត្តមសេនីយ៍ប៉ូលិស ឌុល គៀន

ដោយ : សីហា

បញ្ហាផ្ទៃក្នុង នៅក្នុងគណបក្សប្រជាជន វាមិនមែនមានតែក្រុម បក្ខពួកធំៗ រវាងខ្សែលោក*ហ៊ុន សែន*, ខ្សែលោក*ជា ស៊ីម*, ខ្សែលោក*សាយ ឈុំ* និងខ្សែលោក*ហេង សំរិន* ទេ, គឺពិសេសនោះ មានក្រុម និង

តទៅទំព័រ២ ស

# រដ្ឋាភិបាល ហ៊ុន សែន ថាមិនដឹងពេលណាដោះស្រាយបញ្ហាជាមួយសៀមរួចនោះទេ


លោក ហ៊ុន សែន នាយករដ្ឋមន្ត្រីខ្លាំងតែជាមួយខ្មែរគ្នាឯង


សាម៉ាក់ នាយករដ្ឋមន្ត្រីសៀម


ព្រះមហាក្សត្រសៀម

ដោយ : គ.អរពិន្ទ

បើទោះបីជាមានការជ្រើសតាំងរដ្ឋមន្ត្រីការបរទេសទី៣នៃរដ្ឋាភិបាលសៀម *សាម៉ាក់ ស៊ុនដារ៉ាវេត*ឱ្យចូលមកកាន់តំណែង ហើយក៏មានការសង្ឃឹមបែបស្រពិចស្រពិលពីសំណាក់រដ្ឋាភិបាលគណបក្សប្រជាជន *ហ៊ុន សែន* ចំពោះដំណើរការនៃការបើកការចរចាថ្នាក់ខ្ពស់រវាងប្រទេសទាំងពីរឡើងវិញអំពី

តទៅទំព័រ២ ន

# ប្រជាពលរដ្ឋនៅស្រុកស្ទឹងត្រង់ប្តឹងក្រុមហ៊ុនឡុងស្រេងដល់ ហ៊ុន ណេង ចៅហ្វាយខេត្តកំពង់ចាម


លោក ហ៊ុន ណេង ចៅហ្វាយខេត្តកំពង់ចាម


លោក សុខ អាន

ដោយ : ជ.ឧត្តម

ប្រជាពលរដ្ឋចំនួន២០០គ្រួសារតំណាងឱ្យប្រជាពលរដ្ឋ ៧១០គ្រួសារនៅស្រុកស្ទឹងត្រង់ បានឡើងមកប្តឹងតវ៉ាដល់ចៅហ្វាយខេត្តកំពង់ចាមឈ្មោះ *ហ៊ុន ណេង* កាលពីថ្ងៃទី៨ ខែកញ្ញា កន្លងទៅដោយតំណាង

តទៅទំព័រ៣ ឈ

# សាលាដំបូងខេត្តកំពង់ធំត្រូវតែចាត់ការជនល្មើសខេងកឿ

ដោយ : គ.រដ្ឋា

ឈ្មោះ *ខេង កឿ* ដែលជាក្រុមប្រឹក្សាឃុំស្រើង ស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ ត្រូវបានលោក *ម៉ែន សុថាវរិន្ទ្រ* ប្រធានស្តីទីគណបក្សសមរង្ស៊ីខេត្តកំពង់ធំដាក់ពាក្យបណ្តឹង

តទៅទំព័រ២ ហ

# ជេមស៊្បិន គ្រោងអភិវឌ្ឍន៍ជាមួយ កុល សុខុម លើទំហំដី៤.០០០ហិកតានៅខេត្តសៀមរាប


លោកស្រី កុល សុខុម និងតារាភាពយន្ត ជេមស៊្បិន

ដោយៈ សច្ចៈ

បន្ទាប់ពីបញ្ចប់ ទស្សនកិច្ចរយៈពេល២សប្តាហ៍នៅកម្ពុជា តារាភាពយន្ត ដ៏ល្បីឈ្មោះនៅលើពិភពលោក ហូលីវូដ *ជេមស៊្បិន* ដែលមានរហស្សនាមថា ០០៧នោះ មានគំរោងធ្វើការអភិវឌ្ឍន៍ តំបន់ទេសចរណ៍ជាច្រើន នៅក្នុងអាណាចក្រខ្មែរជាមួយលោកស្រី*កុលសុខុម* ។ តារាភាពយន្ត*ជេម ស៊្បិន* ដែល

តទៅទំព័រ៣ ជ

ស្រូវទុំ កំរងកែវ

ភោជនីយដ្ឋាន **កំរងកែវ** អតីតភោជនីយដ្ឋាន **ស្រូវទុំ** ឥឡូវនេះបានបើកឡើងវិញហើយ ដោយប្តូរឈ្មោះថា **កំរងកែវ** ដោយប្តូរទាំងចៅកែ ។

លោក មាស គន្ធី ដែលជាអតីតចៅកែភោជនីយដ្ឋាន **ស្រូវទុំ** ត្រូវបានផ្លាស់ប្តូរដោយចៅកែថ្មីដែលមានជំនាញពិសេសល្អលើសចៅកែចាស់ (ស្រូវទុំ) ទ្វេដង ពីព្រោះចៅកែថ្មី និងចុងភៅសុទ្ធតែមានបទពិសោធយូរឆ្នាំ និងមានជំនាញច្បាស់លាស់ ។

អាស្រ័យហេតុនេះ សូមអញ្ជើញភ្ញៀវទាំងអស់មកភ្លក្សរស់ជាតិដែលជាស្នាដៃរបស់ចៅកែ និងចុងភៅថ្មី និងមានការរៀបចំយ៉ាងពិសេសសម្រាប់ភ្ញៀវទាំងអស់ដែលបានអញ្ជើញមកពិសានៅភោជនីយដ្ឋានយើងខ្ញុំ ។

**បញ្ជាក់** : ចំពោះភ្ញៀវដែលអញ្ជើញមកពិសានៅភោជនីយដ្ឋាន **កំរងកែវ** យើងខ្ញុំដោយភ្ជាប់ជាមួយនឹងប័ណ្ណជូនដំណឹងក្នុងសារព័ត៌មានខ្មែរម្ចាស់ស្រុកនេះ យើងខ្ញុំនឹងបញ្ចុះតម្លៃជូន១០% ។

អាស័យដ្ឋាន ផ្ទះលេខ៤២ ផ្លូវ២៨៩ កែងសាលាទួលគោក "ពៅអ៊ុំ"

ដំណឹងពិសេសដ៏អស្ចារ្យ

ពីលោកគ្រូ **ហោ លីម** ព្យាបាលតាមរបៀបម៉ាស្សា លាប រឹត ស្ពំ ថ្នាំបុរាណខ្មែរ ធូរស្បើយក្នុង រយៈពេល **១ម៉ោង (មិនធូរស្បើយមិនគិតលុយ)** នូវជំងឺមនុស្សចាស់ ចុកចាប់ក្នុងរាងកាយ, ឈឺក្បាលជាយូរឆ្នាំក្តី, ឈឺជង្គង់, ឈឺសន្លាក់ដៃ សន្លាក់ជើង, រោយឆ្អឹងខ្នង, តឹងច្រមុះ, តឹងទ្រូង, ថប់ដង្ហើម, ញ័រទ្រូង, ទល់ឆ្អល់ក្នុងពោះ, ពិបាកបត់ជើងតូចធំ, ជាពិសេសជំងឺ១០០មុខក្នុង រាងកាយ ។ល។ **ផ្នែកសម្រស់ :** សង្វាពោះក្រាស់ ជាំមុខ គ្មានដោះ ឬដោះស្បែត ព្យាបាល យ៉ាងស័ក្តិសិទ្ធិ។

- មានបន្ទប់បុរស ស្ត្រី ដាច់ដោយឡែកពីគ្នា
- មានលក់ថ្នាំសម្រាប់ព្យាបាលដោយខ្លួនឯង

ទីតាំងផ្ទះលេខ០៧៧ **ហោ លីម ថែសម្ផស្ស** ច្រកចូលផ្លូវមានដំបូល ជាប់របងស្ពានចាស់ សង្កាត់ស្រះចក ខណ្ឌដូនពេញ

ទូរស័ព្ទទំនាក់ទំនង : **012 363 331, 016 719 616,**

## *បរិយាយថ្ងៃនេះ*

# ក្រោយការបោះឆ្នោតរាស្ត្រអស់សង្ឃឹមថាស៊ីភីភីមិនអាចជួយអ្វីដល់រាស្ត្រនោះទេ

ដោយ : មាឌុរ ប្រាថ្នា

ការបោះឆ្នោត បានកន្លងផុតទៅរយៈពេលជិតពីរខែទៅហើយ ហើយ អ្វីដែលជាសេចក្តីរំពឹងរបស់ប្រជារាស្ត្រនោះ គឺចង់ឃើញរដ្ឋាភិបាលថ្មីដោះស្រាយបញ្ហាដែលកើតឡើងរួមវិតជីវភាពរបស់ប្រជារាស្ត្រដូចជាភាពក្រីក្រ ការរំលោភយកដីធ្លី ការជិះជាន់ ការគំរាមកំហែងបំភិតបំភ័យ ក៏ដូចជាការប្លន់យកដីប្រជារាស្ត្រនិងអំពើពុករលួយសព្វសារពើជាពិសេស

តទៅទំព័រ៤ ក

**តមកពីទំព័រ១ ន**

បញ្ហាព្រំដែនក៏ដោយ ក៏មន្ត្រីនៃទីស្ដីការគណៈរដ្ឋមន្ត្រីរដ្ឋាភិបាលក្រុងភ្នំពេញបាននិយាយអំពីការមិនដឹងពេលវេលា និងការដោះស្រាយបញ្ហាគ្នារួចនៅពេលណាឡើយ ។

លោក *ផៃ ស៊ីផាន* ជាអ្នកនាំពាក្យនៃទីស្ដីការគណៈរដ្ឋមន្ត្រីកាន់កាប់ដោយលោក*សុខអាន* មនុស្សជំនិតបំផុតរបស់នាយករដ្ឋមន្ត្រីខ្មែរ ហើយដែល *សុខអាន* ក៏ជាអ្នកកាន់បញ្ជីឯកសារសំណុំរឿងចរចាជាមួយសៀមនោះ *ផៃ ស៊ីផាន* បាននិយាយថាកម្ពុជាមានក្ដីសង្ឃឹមអំពីការចរចារឬកិច្ចពិភាក្សាខ្មែរសៀមថ្នាក់ខ្ពស់ឡើងវិញឆាប់ៗ ។

ប៉ុន្តែទន្ទឹមនឹងនេះ *ផៃ ស៊ីផាន* ក៏បាននិយាយបន្ថែមថា ពុំដឹងថាតើពេលណាបញ្ហាវិវាទទឹកដីខ្មែរ-សៀមនៅតាមតំបន់ព្រំដែនប្រទេសទាំងពីរនឹងដោះស្រាយរួចនោះឡើយ ។ គឺជាសេចក្ដីសារភាពដែលដូចជាការទទួលស្គាល់ផងដែរនូវបរាជ័យនៃនយោបាយការទូតរបស់រដ្ឋាភិបាលគណបក្សប្រជាជន *ហ៊ុន សែន* ។

អតីតអ្នកការទូតប្រទេសសៀមម្នាក់បានព្រមទទួលយកសំណើសុំឱ្យរូបគាត់ធ្វើជារដ្ឋមន្ត្រីការបរទេសថ្មី នៃរដ្ឋាភិបាលក្រុងបាងកក ក្នុងតំណាក់កាលដែលនាយករដ្ឋមន្ត្រីប្រទេសនេះកំពុងប្រឈមមនឹងគំនាបសង្កត់ឱ្យលាលែងចេញពីតំណែង ។ហើយការឡើងចូលកាន់តួនាទីរបស់រដ្ឋមន្ត្រីការបរទេសសៀមថ្មី *សាហូត ឆាវនៈវីរៈ* ក៏ត្រូវគេជឿថាប្រទេសសៀមផ្ដោតការយកចិត្តទុកដាក់ពិសេសលើបញ្ហាជាផលប្រយោជន៍របស់ខ្លួនជាជាងគិតអំពីបញ្ហាផ្លូវច្បាប់ជាមួយប្រទេសកម្ពុជា ។

តាមមតិរបស់ពួកអ្នកសង្កេតការណ៍ សៀមកំពុងផ្ដោតការយកចិត្តទុកដាក់ក្នុងកង្វល់ខ្លាំងរបស់ខ្លួនអំពីមុខមាត់កិត្តិយសរបស់ខ្លួននៅលើឆាកអន្តរជាតិនោះទៅវិញ ជាជាងចង់បានដំណោះស្រាយជាមួយកម្ពុជាលើបញ្ហាព្រំដែននោះ ។ នេះក៏ពីព្រោះថាបច្ចុប្បន្ននេះប្រទេសសៀមគឺជាប្រធានប្រចាំវេននៃសមាគមន៍អាស៊ាន ។ តួនាទីនេះតម្រូវឱ្យសៀមជាអ្នករៀបចំបានប្រារព្ធនូវពិធីនានានៃសមាគមប្រទេសនេះ ដូច្នេះវាគឺជាមុខមាត់នៃប្រទេសសៀមជាសំខាន់ ។

មានកង្វល់នៅក្នុងបណ្ដាអ្នកនយោបាយជាន់ខ្ពស់សៀមថាបើប្រទេសសៀមនៅតែពុំមានរដ្ឋមន្ត្រីការបរទេសរបស់ខ្លួនជាមេការទូតក្នុងកិច្ចការអន្តរជាតិឱ្យបានឆាប់ទេនោះប្រទេសសៀមខ្លួនឯងនេះនឹងបាត់បង់មុខមាត់កិត្តិយស ព្រោះខ្លួនមានតួនាទីជាប្រធានចាំវេននៃសមាគមអាស៊ាននេះ ។

ដូច្នេះហើយគោលដៅធំបំផុតនៃការចង់បានរដ្ឋមន្ត្រីការបរទេសថ្មីរបស់សៀមដោយនាយករដ្ឋមន្ត្រី *សាម៉ាក់ ស៊ុនដារ៉ាវេត* នោះគឺដើម្បីស្ដារមុខមាត់សៀមនៅលើឆាកអន្តរជាតិជាពិសេសក្នុងតំបន់ដែលសៀមគឺជាសមាជិកដើងចាស់ម្នាក់របស់សមាគមអាស៊ាននេះ ។

ប៉ុន្តែទន្ទឹមនឹងនេះដែរ ខាងភាគីកម្ពុជា ដូចដែល *ហ៊ុន សែន* បានសម្ដែងកង្វល់កាលពីថ្មីៗនេះ ដាស់តឿនរុញឱ្យ *ហោ ណាំហុង* ប្រញាប់ទាក់ទងសុំធ្វើការចរចាជាមួយសៀមជាថ្មីឡើងវិញ ។ ដូច្នេះតំណាលគ្នានឹងការដែលសៀមជ្រើសតាំងបានរដ្ឋមន្ត្រីការបរទេសថ្មីនោះ ខាងរដ្ឋាភិបាលគណបក្សប្រជាជន *ហ៊ុន សែន* មានសេចក្ដីសង្ឃឹមអំណរក្នុងចិត្តតែឯងថា នោះគឺជាបើកច្រកឱ្យមានការចាប់ផ្ដើមចរចាថ្នាក់ខ្ពស់រវាងកម្ពុជា-សៀមជាថ្មីទៀតជុំវិញបញ្ហាតំបន់ព្រំដែននោះ ។

បើទោះជាយ៉ាងនេះក៏ដោយ ក៏ក្នុងស្ថានភាពដែលនាយករដ្ឋមន្ត្រីសៀមកំពុងប្រឈមមនឹងគំនាបពីកម្លាំងបក្សរួបរួមប្រជាធិបតេយ្យទាមទារឱ្យគាត់ចុះចេញពីតំណែងនោះ ប្រមុខរដ្ឋាភិបាលសៀមក៏គេគិតថា នឹងត្រូវរង់ចាំមើលសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញនៃប្រទេសនេះ ។

ស្ថាប័នកំពូលនេះបានបង្ហាញនូវឆន្ទៈចង់ឱ្យមានការរកដំណោះស្រាយបញ្ចប់វិបត្តិនយោបាយដែលធ្វើឱ្យជ្រួលច្របល់ប្រទេសសៀមបច្ចុប្បន្ននេះ ហើយអ្វីដែលជាដំណោះស្រាយសមស្របត្រូវក្រុមប្រឹក្សាធម្មនុញ្ញដាស់តឿនឱ្យនាយករដ្ឋមន្ត្រី*សាម៉ាក់* ចុះចេញពីអំណាច ។

នេះហើយគឺវានឹងក្លាយទៅជាដើមរឿងនៃបញ្ហាថ្មីដែលនឹងធ្វើឱ្យរដ្ឋាភិបាលនេះត្រូវប្រឈមនឹងវិបត្តិ អាចនឹងត្រូវរំលាយចោល ហើយក៏តម្រូវឱ្យមានការបោះឆ្នោតជាថ្មីឡើងវិញ ។ ពេលនោះប្រទេសសៀមក៏ត្រូវរង់ចាំពេលវេលាយូរទៅទៀតដើម្បីនឹងមានរដ្ឋាភិបាល ហើយនឹងអាចចាត់ចែងកិច្ចការទាំងឡាយរបស់ប្រទេសរៀបរយមុននឹងអាចបើកការចរចាជាមួយកម្ពុជា ។

ដូច្នេះអ្វីដែលជាសេចក្ដីសង្ឃឹមសម្រាប់រដ្ឋាភិបាលគណបក្សប្រជាជន *ហ៊ុន សែន* នៅពេលនេះ ក៏គ្រាន់តែជាលក្ខណៈស្រមោលនៃភាពមិនច្បាស់ ។ ហើយលើសពីនេះទៅទៀត នេះក៏បង្ហាញឱ្យឃើញថា រដ្ឋាភិបាល *ហ៊ុន សែន* កំពុងព្រួយបារម្ភយ៉ាងខ្លាំងចំពោះបញ្ហាជាកំហុសនយោបាយរបស់ខ្លួនដែលមិនត្រឹមតែធ្វើអ្វីៗតាមការទាមទាររបស់សៀម ក៏ថែមទាំងមិនហ៊ានប្រើប្រាស់សិទ្ធិនៃប្រជាជាតិមួយដើម្បីទប់មិនឱ្យទាហានសៀមឈ្លានពានកាន់កាប់ដីខ្មែរនោះ ។

ចាប់តាំងតែពីថ្ងៃទី១៥ ខែកក្កដា មុនការបោះឆ្នោតនៅកម្ពុជាមកម្ល៉េះ គណបក្សប្រជាជនបានបើកយុទ្ធនាការយកប្រាសាទព្រះវិហារធ្វើជាប្រធានបទនៃការឃោសនានយោបាយរកសន្លឹកឆ្នោតឱ្យខ្លួន ។ ហើយពេលនោះសៀមបានលើកទាហានឈ្លានពានចូលកាន់កាប់វត្តកែវសិក្ខាគិរីស្វារៈ ហៅវត្តប្រាសាទព្រះវិហារ នៅក្បែរប្រាសាទព្រះវិហារ ។

បន្ទាប់ពីនោះមក បើទោះបីជាមានការបើកការចរចាថ្នាក់ខ្ពស់ច្រើនលើកច្រើនសារក៏អ្វីៗហាក់បីដូចជាកលល្បិចរបស់សៀមក្នុងការអូសបន្លាយពេលវេលាដើម្បីឆ្លៀតកេងចំណេញនយោបាយ ក៏ដូចជាចំណេញផ្នែកទឹកដីលើកម្ពុជាបន្ថែមទៀត ។ ជំនួបថ្នាក់មេទ័ពកំពូលរបស់ជាតិនៃប្រទេសទាំងពីរ ក៏ដូចជាថ្នាក់ការទូតរបស់ប្រទេសទាំងពីរនៅតែមិនបានផលចំពោះការឱ្យទាហានសៀមដកចេញពីទឹកដីខ្មែរនោះទេ ។

នៅថ្ងៃទី២១ កក្កដា ជាថ្ងៃដែលកម្ពុជាដំបូងឡើងដើរតាមជំហានត្រូវ ដោយដាក់ពាក្យបណ្ដឹងប្ដឹងទៅក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិឱ្យធ្វើអន្តរាគមន៍នោះ សៀមបានសុំឱ្យមានជំនួបថ្នាក់ខ្ពស់កម្ពុជាចេញមុខដោយរដ្ឋមន្ត្រីការពារជាតិ *ទៀ បាញ់* និងសៀមមានអគ្គមេបញ្ជាការកងយោធពលថៃ *ប៊ុនស្រាង និយមប្រាឌិត* ជាតំណាងចរចាគ្នានៅឯខេត្តស្រះកែវ ប្រទេសសៀម ។

នៅឯជំនួបនោះសៀមបានសុំនូវលក្ខខណ្ឌយ៉ាងច្រើន ក្នុងនោះមានទាំងការទាមទារឱ្យកម្ពុជាព្រមចែកផលប្រយោជន៍ប្រមាណដល់ទៅពាក់កណ្ដាលពីប្រាក់ចំណូលដែលកម្ពុជាត្រូវបានពីវិស័យទេសចរណ៍នៅតំបន់ប្រាសាទព្រះវិហារក៏ដូចជាសៀមទាមទារឱ្យទាហានខ្មែរដកចេញពីទឹកដីខ្មែរនៅតំបន់នោះផងក្នុងបណ្ដារលក្ខខណ្ឌនានា ។ការចរចានោះបាននាំទៅដល់អ្វីដែលជាបរាជ័យ ថ្វីបើមានការបើកការចរចាថ្នាក់រដ្ឋមន្ត្រីការបរទេសនៅថ្ងៃទី២៨ ខែកក្កដា រវាង *ហោ ណាំហុង* និង *តេជ ប៊ុនណាក* រដ្ឋមន្ត្រីការបរទេសទី២នៃរដ្ឋាភិបាល *សាម៉ាក់*នៅក្រុងសៀមរាប កាលពីថ្ងៃទី២៨ ខែកក្កដា ។

ការចរចានេះគ្រាន់តែបាននិយាយគ្នា ឱ្យមានឈ្មោះថាបាននិយាយហើយពុំបានផលអ្វីជាច្បាស់លាស់នោះទេ ។ ប៉ុន្តែវាក៏បាននាំទៅដល់ជំនួបថ្នាក់កំពូលនៃមេការទូតមួយលើកទៀតនៅទីកដីហូរហ៊ិន នៃប្រទេសសៀម នៅថ្ងៃទី១៨-១៩ ខែសីហា ។ បន្ទាប់ពីជំនួបនោះ មិនដឹងជាដោយហេតុផលអ្វី *ហ៊ុន សែន* បានប្រើឱ្យ *ហោ ណាំហុង* ទៅក្រាបបង្គំស្ដេចសៀម ហើយនៅក្រោយជំនួបនោះ គេបានឮ *ហោ ណាំហុង* និយាយអួតអំពីការដែលកម្ពុជាធ្វើសម្បទានឱ្យសៀម ។

*ហោ ណាំហុង* បាននិយាយថា ដំណើរការចរចាររវាងខ្មែរសៀមប្រព្រឹត្តទៅមុខជានិច្ចគ្រាន់តែក្នុងល្បឿនដូចរូឡ គឺយឺតៗ ។ *ហោ ណាំហុង* ថែមទាំងបាននិយាយអួត ដោយមិនបានគិតថាខ្លួនឯងចាញ់បោកសៀមសុទ្ធសាធនោះទេ ពេលដែលមេការទូតខ្មែរ *ហោ ណាំហុង* និយាយក្នុងនាម *ហ៊ុន សែន*ថាកម្ពុជាយល់ព្រមដោយឯកឯង មិនចាំបាច់ឱ្យសៀមទាមទារទេក្នុងការដកបណ្ដឹងរបស់ខ្លួននៅអង្គការសហប្រជាជាតិ ។ មួយករណីទៀតនោះ គឺ *ហោ ណាំហុង* បានប្រាប់អ្នកកាសែតថា កម្ពុជាក៏បានប្រាប់ភាគីសៀមដែរថា មិនបាច់សៀមទាមទារទេក៏កម្ពុជាយល់ព្រមដកទាហានខ្មែរពីប្រាសាទព្រះវិហារ ដែលសៀមទទួល

**តទៅទំព័រ៣ ន**

**តមកពីទំព័រ១ ស**

បក្ខពួក នៅក្នុងខ្សែនីមួយៗទៀតផង ជាពិសេសខ្សែលោក *ហ៊ុន សែន* គឺមានក្រុមសម្បើមណាស់ ដែលក្រុមខ្លះមាននៅក្នុងជួរនគរបាល, ក្រុមខ្លះនៅក្នុងជួរទាហាន, ក្រុមខ្លះ នៅក្នុងរដ្ឋសភា ។

ប៉ុន្តែអ្នកចំណូលថ្មីដែលលក់ឧត្តមគតិ ផ្ដាច់ខ្លួនមួយដំបរស្វាទៅពីគណបក្សសម រង្ស៊ី នៅមុនបោះឆ្នោតនោះ ក៏បង្កើតជាក្រុម ជាបក្ខពួក នៅក្នុងខ្សែរបស់លោក*ហ៊ុន សែន* ដែរ គឺមានអ្នកខ្លះ ធ្វើឱ្យនាយឧត្តមសេនីយ៍ផ្កាយមាស៤នៅក្រសួងមហាផ្ទៃលោះព្រលឹង ម្ដងៗទៀតផង ។

អ្នកលក់ឧត្តមគតិម្នាក់ បានអោយដឹងថា អតីតសមាជិកសភាម្នាក់ របស់គណបក្សសមរង្ស៊ី ដែលបានលក់ឧត្តមគតិចុះចូលគណបក្សប្រជាជន តាមរយៈ លោក*ឌុល គឿន* នាយឧត្តមសេនីយ៍ផ្កាយមាស៤ និងជាអគ្គស្នងការរង នគរបាលជាតិនោះ កំពុងបង្កើតជាក្រុមនៅក្នុងគណបក្ស ធ្វើឱ្យលោក *ហ៊ុន សែន* ឈឺក្បាលយ៉ាងខ្លាំង ។ អតីតអ្នកតំណាងរាស្ត្ររូបនោះ ដែលល្បីថា កំពុងតែមានបញ្ហាផ្ទៃក្នុងគ្រួសារដោយសារភ្លើតភ្លើន ជាមួយស្រីនៅក្រៅផ្ទះនោះ បានងាកទៅឱបជើងលោក*ហុក ឡុងឌី* អគ្គនាយកនគរបាលជាតិ ហើយក៏ពើងទ្រូងដាក់លោក*ឌុល គឿន* វិញយ៉ាងក្រអឺតក្រទម ។

មន្ត្រីគណបក្សប្រជាជនបានឱ្យដឹងថា ទាំងលោក*ហុក ឡុងឌី* ទាំងលោក*ឌុល គឿន* គឺសុទ្ធតែជាខ្សែលោក*ហ៊ុន សែន*ទាំងអស់គ្នា, ហើយអ្នកទាំងពីរបានធ្វើអោយលោក*ហ៊ុន សែន* ឈឺក្បាលសម្បើមណាស់ កាលពីមុនបោះឆ្នោត ។

លោកនាយ ឧត្តមសេនីយ៍ *ហុកឡុងឌី* ចាប់ផ្ដើមឈឺក្បាលនឹងពួកឱកាសនិយម មួយដំបរស្វាដែរហើយ ដោយសារតែរយៈពេលចុងក្រោយនេះ មានអ្នកសុំចុះចូល គណបក្សប្រជាជននៅមុនបោះឆ្នោតទាំងនោះ បានបង្កើតជាក្រុមតូចៗ រត់រកខ្នងបង្អែក ដែលបញ្ហានេះបានធ្វើឱ្យថ្នាក់ដឹកនាំគណបក្សប្រជាជន ឈឺក្បាលមួយកំរិតទៀតគឺឈឺក្បាលនឹងសមាជិកសភាគណបក្សសម រង្ស៊ី និងគណបក្សសិទ្ធិមនុស្ស មិនចូលរួមប្រជុំនៅថ្ងៃដំបូងផង និងកំពុងឈឺក្បាល នឹងចោរសៀមឈ្លានពានបូរណភាពទឹកដីមិនឈប់មិនឈរផង, ហើយមកឈឺក្បាលនឹងអ្នកលក់ឧត្តមគតិមួយដំបរស្វាផង ។

ប្រភព ពីអ្នកលក់ឧត្តមគតិម្នាក់បានឱ្យដឹងថា អ្នកចុះចូលគណបក្សប្រជាជនខ្លះ មិនត្រឹមតែបង្កើតក្រុម ចង់បានឥទ្ធិពលរៀងៗខ្លួននោះទេ គឺមានអ្នកខ្លះ បង្កើតរឿងចាក់រុកចង់ផ្តួលមន្ត្រីគណបក្សប្រជាជន ដែលតស៊ូជាមួយបក្ស តាំងពីនៅឆ្នាំ១៩៧៩ទៀត ។

ប្រភព បានឱ្យដឹងទៀតថា នៅក្នុងចំណោម អ្នកលក់ឧត្តមគតិទាំងនោះ គេឃើញលោក *ឱម គឹមស៊ា* ហាក់ដូចជាយ៉ាប់ជាងគេ គឺអោយតែឮសូរភ្លេងមិនបាន ចង់តែរាំ បើទោះបីជាភ្លេងខ្លះ ត្រូវបានគេចាក់អោយភ្ញៀវស្ដាប់ជាទូទៅក៏ដោយ ។

ប្រភពបានឱ្យដឹងថា ថ្នាក់ដឹកនាំ គណបក្សប្រជាជនខ្លះ បានផ្ដល់រហស្សនាម ឱ្យលោក *ឱម គឹមស៊ា* ថា ជាមន្ត្រីស្មារពីព្រោះឮភ្លេងមិនបាន ។ ប៉ុន្តែអ្វីដែលលោក*ហ៊ុន សែន* ឈឺក្បាលនោះគឺពួកនេះបានបង្កើតក្រុមនៅក្នុងខ្សែបង្កើតខ្សែបក្ខពួក នៅក្នុងគណបក្សប្រជាជនដូចគ្នា ដែលគេជឿថា គណបក្សប្រជាជន នឹងជួបមហាស្នគស្នាញ មិនងាយនឹងដោះស្រាយដោយស្រួលៗឡើយ ៕

**តមកពីទំព័រ១ ហ**

ទៅព្រះរាជអាជ្ញាអមសាលាដំបូងខេត្តកំពង់ធំរួចហើយកាលពីថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០០៨ កន្លងទៅ ។

ប្រការដែលលោក *ម៉ែន សុថាវិទ្រ* ប្ដឹងពីឈ្មោះ *ខេង កឿ* យ៉ាងដូច្នេះ គឺបណ្ដាលមកពី *ខេង កឿ* នេះថ្លើមធំហ៊ានចេញលិខិតក្លែងក្លាយ (ទម្រង់ ១០១៨) ឱ្យឈ្មោះ *ជឿង គា* យកទៅបោះឆ្នោតកាលពីថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ២០០៨ ។

ក្នុងពាក្យបណ្ដឹងរបស់លោក *ម៉ែន សុថាវិទ្រ* ប្រធានស្ដីទីគណបក្សសមរង្ស៊ី ប្រចាំខេត្តកំពង់ធំបានបញ្ជាក់យ៉ាងដូច្នេះថា "*ខ្ញុំសូមជម្រាបលោកព្រះរាជអាជ្ញាមេត្តាជ្រាបថា កាលពីថ្ងៃទី២៧ខែកក្កដា ឆ្នាំ២០០៨ ឈ្មោះជឿង គាបានកាន់ទម្រង់ ១០១៨ក្លែងក្លាយដែលមិនមែនជាឈ្មោះពិតរបស់ខ្លួនចេញដោយក្រុមប្រឹក្សាឃុំស្រើង យកទៅបោះឆ្នោត* " ។

បណ្ដឹងលោក *ម៉ែន សុថាវិទ្រ* បានបន្តទៀតថា ឈ្មោះ *ជឿង គា* នេះបានយកទម្រង់ ១០១៨ក្លែងក្លាយទៅបោះឆ្នោតនៅមណ្ឌលបោះឆ្នោតក្នុងភូមិទំនប់ ឃុំស្រើង ស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ ។

ដោយសារតែលិខិតក្លែងក្លាយនេះ (ទម្រង់បែបបទ ១០១៨) ទើបគេធ្វើឱ្យជនដែលពុំមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការបោះឆ្នោតអាចចូលទៅបោះឆ្នោតបានដោយខុសច្បាប់ ។

លោក *ម៉ែន សុថាវិទ្រ*បានបញ្ជាក់យ៉ាងច្បាស់ថា "*ទង្វើរបស់ឈ្មោះ ខេង កឿ ក្រុមប្រឹក្សាឃុំស្រើង ស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំនេះគឺជាអំពើល្មើសច្បាប់ព្រហ្មទណ្ឌអន្តរកាលយ៉ាងធ្ងន់ធ្ងរដែលតម្រូវឱ្យមានការចាត់វិធានការតាមផ្លូវច្បាប់ទៅលើឈ្មោះ ខេង កឿ ឱ្យបានម៉ឺងម៉ាត់បំផុត* " ។

គួរបញ្ជាក់ថាគណបក្សសមរង្ស៊ីបានប្ដឹងតវ៉ាយ៉ាងសកម្មប្រឆាំងនឹងលទ្ធផលឆ្នោតក្លែងក្លាយដែលកើតចេញពីការបាត់ឈ្មោះអ្នកមានសិទ្ធិបោះឆ្នោតយ៉ាងច្រើនសន្ធឹកសន្ធាប់នៅទូទាំងប្រទេស ។ ហើយអ្វីដែលគណបក្សសមរង្ស៊ីយល់ថា មេឃុំ-ចៅសង្កាត់ ក៏ដូចជាក្រុមប្រឹក្សាឃុំ-សង្កាត់ រួមនិងមេភូមិ អនុភូមិ បានប្រព្រឹត្តអំពើល្មើសច្បាប់ហ៊ានចេញលិខិតក្លែងក្លាយ (ទម្រង់ ១០១៨) នោះគឺត្រូវតែប្រឈមមុខនឹងការផ្ដន្ទាទោសក្រោមច្បាប់ព្រហ្មទណ្ឌអន្តរកាលត្រង់មាត្រា៤៩ ដោយគ្មានការលើកលែងឡើយ ។

កន្លងមកមេធាវី *គង់សំអុន* ដែលតំណាងឱ្យគណបក្សសមរង្ស៊ីក្នុងនាមជាដើមបណ្ដឹងធ្លាប់បានរៀបរាប់យ៉ាងលំអិតឱ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត(គ.ជ.ប) និងក្រុមប្រឹក្សាធម្មនុញ្ញដើម្បីឱ្យចាត់ការជនល្មើសតាមផ្លូវច្បាប់ព្រហ្មទណ្ឌអន្តរកាលត្រង់មាត្រា៤៩ ស្ដីពីការក្លែងបន្លំអក្សរក្នុងឯកសារសាធារណៈ ។

ទាក់ទិននឹងច្បាប់ព្រហ្មទណ្ឌអន្តរកាលនេះដែរ ត្រូវបានមេធាវី*គង់ សំអុន* អត្ថាធិប្បាយថា អំពើនៃការក្លែងទម្រង់បែបបទ ១០១៨ របស់ គ.ជ.ប គឺជាការប៉ះពាល់ដល់ច្បាប់ព្រហ្មទណ្ឌ ដោយសារមាត្រា៤៩ នៃបទបញ្ញត្តិស្ដីពីប្រព័ន្ធតុលាការច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌសម្រាប់អនុវត្តន៍នៅប្រទេសកម្ពុជាក្នុងសម័យអន្តរកាលដែលបានអនុម័តដោយក្រុមប្រឹក្សាជាតិជាន់ខ្ពស់, ដោយសេចក្ដីសម្រេចចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៩២ ដែលគេនិយមហៅថា ច្បាប់ព្រហ្មទណ្ឌអន្តរកាល ឬច្បាប់អ៊ុនតាក់ បានកំណត់ទោសចំពោះអំពើក្លែងបន្លំបែបនេះ ។

ដោយឡែកបើនិយាយអំពីមាត្រា៤៩នោះ បានចែងថា "*គ្រប់ជនជ្រើសតាំងដោយការបោះឆ្នោត, គ្រប់អ្នករដ្ឋការស៊ីវិល ឬយោធា, គ្រប់ភ្នាក់ងារផ្លូវការរបស់ភាគីណាមួយក្នុងបណ្ដាភាគីខ្មែរទាំង៤នៃកិច្ចព្រមព្រៀងក្រុងប៉ារីស ឬរបស់គ្រប់គណបក្សនយោបាយដែលបានចុះក្នុងបញ្ជីដែលក្នុងការងាររបស់ខ្លួនបានប្រព្រឹត្តបទក្លែងដោយក្លែងហត្ថលេខា ឬដោយលួចលិខិតផ្លូវការ កែអក្សរ ឬកែហត្ថលេខា ដោយសន្មតជនម្នាក់ថា ជាជនម្នាក់ទៀតដោយធ្វើអក្សរ ឬស៊កបញ្ចូលអក្សរលើបញ្ជី ឬលិខិតសាធារណៈផ្សេងៗ ចាប់ពីការធ្វើការ ឬការបញ្ចប់បញ្ជី ឬលិខិតសាធារណៈនោះ ។ អ្នកណាដែលបានប្រើប្រាស់ដោយដឹងខ្លួននូវរបស់ក្លែងក្លាយអស់ទាំងនោះ នឹងត្រូវមានទោសឧក្រិដ្ឋពីបទក្លែងលិខិតសាធារណៈហើយត្រូវតែផ្ដន្ទាទោសពី៥ឆ្នាំទៅ១៥ឆ្នាំ* " ។

ក្រុមមន្ត្រីគណបក្សសមរង្ស៊ីបានឱ្យដឹងថា ការប្ដឹងមេឃុំចៅសង្កាត់ ក៏ដូចជាមេភូមិ អនុភូមិទៅតុលាការដែលសុទ្ធតែជាមនុស្សរបស់គណបក្សប្រជាជននោះគឺត្រូវតែធ្វើក្នុងលក្ខណៈទ្រង់ទ្រាយធំបំផុត ។ ហើយប្រសិនបើតុលាការគ្រប់ខេត្ត-ក្រុងមានជំហរឯករាជ្យពិតប្រាកដមែននោះ គេជឿថាអ្នកដែលហ៊ានចេញទម្រង់១០១៨ក្លែងក្លាយនេះ គ្មាននរណាម្នាក់ត្រូវរួចខ្លួនពីការជាប់ទោសជាដាច់ខាត ។

គេសង្ឃឹមថា ឈ្មោះ *ខេង កឿ* ដែលជាក្រុមប្រឹក្សាឃុំស្រើង នឹងត្រូវផ្ដន្ទាទោសតាមច្បាប់ព្រហ្មទណ្ឌអន្តរកាលដោយសាលាដំបូងខេត្តកំពង់ធំជាមិនខាន៕

**តមកពីទំព័រ១ ឈ**

ប្រជាពលរដ្ឋរងគ្រោះទាំងនោះ បានថ្លែងថាក្រុមហ៊ុនឡុងស្រេង បានរំលោភលើកិច្ចសន្យាឈូស ដើមកៅស៊ូចោល ដែលខាងខុទ្ទកាល័យនាយករដ្ឋមន្ត្រី *ហ៊ុន សែន* មិនឱ្យភាគីទាំងសង្ខាង ប៉ះពាល់លើដីទំនាស់ជាង១៤០០ ហិកតានោះទេ គឺត្រូវរង់ចាំឱ្យថ្នាក់លើដោះស្រាយជាមុនសិន។

ប៉ុន្តែប្រជាពលរដ្ឋខ្លះបានអះអាងថាដីរបស់ពួកគាត់នេះបានកាន់កាប់តាំងពីឆ្នាំ១៩៨២មកម្ល៉េះ។ ហើយក្នុងឆ្នាំ២០០៦ពួកគាត់បានដាំដើមកៅស៊ូ។ តែវាជាប្រការមួយគួរឱ្យសោកស្តាយណាស់ ព្រោះកាលពីថ្ងៃទី៥ ខែកញ្ញា កន្លងទៅនេះ ក្រុមហ៊ុនឡុងស្រេងបានយកគ្រឿងចក្រទៅឈូសឆាយដើមកៅស៊ូរបស់ពួកគាត់ចោល។ ហើយទង្វើដ៏អាក្រក់បែបនេះ ក៏ល្មើសនឹងកិច្ចសន្យារបស់នាយរងខុទ្ទកាល័យលោក *ហ៊ុន សែន* គឺលោក *លឹម លាងសែ* ដែលធ្លាប់ចុះទៅត្រួតពិនិត្យកាលពីថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ បានហាមភាគីទាំងពីរមិនឱ្យប៉ះពាល់លើដីជម្លោះនោះឡើយ។

ស្ត្រីម្នាក់បានបញ្ចេញប្រតិកម្មថា "*ខ្ញុំមានអារម្មណ៍ថា ខ្ញុំខឹង ព្រោះអីខ្ញុំអត់លុយ ខ្ញុំប្រឹងទាំងត្រដាបត្រដួសអត់ឃ្លាន គ្មានស៊ីបានប៉ុណ្ណឹង ដល់តែគេមកឈូសឆាយដើមកៅស៊ូខ្ញុំចោលអញ្ចឹងទៅតើឱ្យខ្ញុំរំពឹងស្អីទៀត*"?

ទោះជាដូច្នេះក្តី ប្រធានក្រុមហ៊ុន ឡុងស្រេង គឺលោក *ហេង ឡុង* បានបដិសេធចំពោះការចោទប្រកាន់នេះទាំងស្រុង ថាក្រុមហ៊ុនមិនបានប៉ះពាល់លើដីប្រជាពលរដ្ឋណានោះទេ។

យ៉ាងណាក៏ដោយ ប្រជាពលរដ្ឋបានអះអាងក្រោយពីចូលជួបអគ្គលេខាធិការខេត្តកំពង់ចាមថា ពួកគាត់មិនអាចទ្រាំនឹងការធ្វើបាបរបស់ក្រុមហ៊ុនឡុងស្រេងម្តងហើយម្តងទៀតបានទេ។ ហើយបើនៅតែមានការរំលោភបំពានបែបនេះទៀត គឺអាចនឹងមានអំពើហិង្សាដាក់គ្នានៅពេលណាមួយជាមិនខាន។

តំណាងប្រជាពលរដ្ឋមួយរូបបានបញ្ជាក់យ៉ាងដូច្នេះថា "*កាលពីថ្ងៃទី១៧ ខែកក្កដា ពេលទៅដល់ភ្នំពេញ គឺលោក លឹម លាងសែ បានសន្យាថា កន្លះខែទៀតលោកនឹងចុះទៅដោះស្រាយ។ តែប្រជាពលរដ្ឋរងគ្រោះមិនបានឃើញលោក លឹម លាងសែ ចុះទៅសោះ ទើបប្រជាពលរដ្ឋមកសាកសួរនៅឯសាលាស្រុកស្ទឹងត្រង់ដឹងថា គេបានធ្វើរបាយការណ៍រួចអស់ហើយ តែមកទើរនៅត្រឹមសាលាខេត្តកំពង់ចាមហ្នឹងតែម្តង*"។

ពុំមានការអត្ថាធិប្បាយណាមួយពីលោក *ហ៊ុន ណេង* ចៅហ្វាយខេត្តកំពង់ចាមទាក់ទិននឹងជម្លោះរវាងក្រុមហ៊ុនឡុងស្រេង និងប្រជាពលរដ្ឋចំនួន ៧១០គ្រួសារនោះឡើយ។ប៉ុន្តែគេឆ្ងល់ថាបើគង់តែដោះស្រាយដដែលជាដដែលនោះ ហេតុអ្វីក៏មិនព្រមដោះស្រាយឱ្យចប់សព្វគ្រប់ភ្លាមៗទៅ ? ឬមួយត្រូវទុកវិបត្តិដីធ្លីនេះឱ្យបន្តអូសបន្លាយដល់ឆ្នាំ២០១៣ ដើម្បីកេងចំណេញសន្លឹកឆ្នោតទៀត?

តាមពិតទៅក្រោមការដឹកនាំរបស់នាយករដ្ឋមន្ត្រី *ហ៊ុន សែន* គេបានសង្កេតឃើញយ៉ាងជាក់ស្តែងថា ទោះជាមានអាជ្ញាធរជាតិស្អេកស្កះដូចម្រាមដៃ យ៉ាងណាក៏ដោយ ក៏ទំនាស់ដីធ្លីនៅតែកើនឡើងស្ទើរពាសពេញផ្ទៃប្រទេស។ ហើយអ្នកដែលអាចដោះស្រាយទំនាស់ដ៏ស្មុគស្មាញនេះបាន គឺមានតែលោក *ហ៊ុន សែន* ម្នាក់គត់។ បានសេចក្តីថា អំណាចអ្វីៗទាំងអស់នៅកម្ពុជា គឺស្ថិតក្នុងកណ្តាប់ដៃលោក *ហ៊ុន សែន* តែម្នាក់ប៉ុណ្ណោះ។

ក្រុមអ្នកវិភាគនានាបានធ្វើការឆ្លុះបញ្ចាំងតាមទស្សនៈថា លោក *ហ៊ុន សែន* មិនអាចបដិសេធបានជាដាច់ខាតពីអ្វីដែលបានលើកឡើងដូចខាងលើ។ ព្រោះលោក *ហ៊ុន សែន* បានធ្វើឱ្យគេឃើញរួចទៅហើយថា លោកជាមនុស្សម្នាក់ដែលល្មោភអំណាចមិនស្កប់ស្កល់។

គេថា អាណត្តិទី៣នេះ ពុំទាន់មានដំណោះស្រាយទំនាស់ដីធ្លីប្រជាពលរដ្ឋដើម្បីឱ្យពួកគាត់បានរស់នៅដោយសុខសាន្តសោះ ពោលគឺនៅតែមានការប្រទាញប្រទង់គ្នារវាងក្រុមហ៊ុន និងប្រជាពលរដ្ឋដដែលៗ ទោះបីជាមានអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីដឹកមុខដោយលោក *សុខ អាន* ជន្លួងលោក *ហ៊ុន សែន* ក៏ដោយ។

មានន័យថា នៅពេលដែលអាជ្ញាធរជាតិជាន់ជើងគ្នាច្រើនពេកទៅ វាមិនខុសអ្វីពីពាក្យថា គ្នាច្រើនអន្សមខ្លោចនោះទេ។ ឥឡូវគេចាំមើលថា តើរដ្ឋាភិបាលអាណត្តិទី៤ដែលនឹងត្រូវបង្កើតឡើងនាពេលខាងមុខនេះ មានក្បាលធំជាងខ្លួនទៅទៀតនោះ តើអាចជួយដោះស្រាយបញ្ហាជាតិបានអ្វីខ្លះ ?

ប្រជាពលរដ្ឋខ្មែរយល់ថា ដរាបណាមានលោក *ហ៊ុន សែន* នៅតែក្រាញនឹងអំណាចដោយមិនឆ្អែតស្កប់ស្កល់នោះ គឺគ្មានអ្វីប្លែកជាងពីអាណត្តិទី៣នោះទេ ព្រោះអ្នកដឹកនាំប្រទេសមុខដដែលៗ ស្ថានភាពប្រទេសជាតិ និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋក៏គ្មានអ្វីប្រែប្រួលដែរ ពោលគឺអ្នកក្រនៅតែក្រដដែល អ្នកមានកាន់តែមានលើសដើមទៅទៀត។

ប៉ុន្តែបើសម្រាប់ប្រជាពលរដ្ឋនៅស្រុកស្ទឹងត្រង់វិញគឺម្នាក់ៗ មានការខឹងសម្បារសម្បើមណាស់ចំពោះអំពើដ៏កម្រោលរបស់ក្រុមហ៊ុនឡុងស្រេងនេះ។

អញ្ចឹងទេ ប្រសិនបើលោក *លឹម លាងសែ* សន្យាថាជួយប្រជាពលរដ្ឋហើយនោះ ក៏គួរតែជួយឱ្យបានដល់កោះត្រើយផង ព្រោះប្រជាពលរដ្ឋដែលកំពុងប្រឈមជាមួយក្រុមហ៊ុនឡុង ស្រេង មានចំនួនដល់ទៅ ៧១០គ្រួសារឯណោះ។

គេថា មន្ត្រីក្រោមក្លៀកលោក *ហ៊ុន សែន* ចូលចិត្តប្រើពាក្យ "*ជីវដ្ឋ*" ដើម្បីបង្ក្រាបរាស្ត្រណាស់។ ប៉ុន្តែគេគួរតែគិតថា "*រដ្ឋក៏កើតចេញពីរាស្ត្រ*" ដែរដែលចាំបាច់ត្រូវគិតគូររាស្ត្រឱ្យបានម៉ត់ចត់ផង ប្រយ័ត្ន "*រដ្ឋរលាយដោយសាររាស្ត្រ*" វិញទៅ៕

ផ្សព្វផ្សាយពាណិជ្ជកម្មលើទំព័រសារព័ត៌មាន ខ្មែរម្ចាស់ស្រុក
ចំណាយតិច និងទៅដល់គ្រប់ទីកន្លែងក្នុងប្រទេសកម្ពុជា

---

**តមកពីទំព័រ១ ៩**

ជាជនជាតិអូស្ត្រាលីនោះ បានជួបជាមួយដៃគូដ៏ចំណានជាប្រធានក្រុមហ៊ុន LLK គឺលោកស្រី*កុល សុខុម* ។

លោកស្រី*កុល សុខុម* បានប្រាប់ *ខ្មែរម្ចាស់ស្រុក* ពាក់ព័ន្ធទៅនឹងគំរោង អភិវឌ្ឍន៍នានា ជាពិសេសនៅតំបន់ទេសចរណ៍សមុទ្រក្រុងព្រះសីហនុ និងតំបន់ទេសចរណ៍អង្គរ នៃខេត្តសៀមរាប ។ លោកស្រីបានបន្តថាតារាភាពយន្ត*ជេម ស្ប៊ន* ដែលជាដៃគូថ្មី សំរាប់ធ្វើការអភិវឌ្ឍន៍នោះបានផ្តោតសំខាន់ធ្វើការអភិវឌ្ឍន៍ នៅលើផ្ទៃដីនៃក្រុងព្រះសីហនុ និងនៅលើផ្ទៃដី ទំហំជាង៤.០០០ហិកតា នៅស្រុកវ៉ារិន ខេត្តសៀមរាបអង្គរ ។

លោកស្រី*កុល សុខុម* បានថ្លែងថា គំរោងរបស់លោកស្រីរួមគ្នាជាមួយលោក*ជេម ស្ប៊ន* ធ្វើការអភិវឌ្ឍន៍នៅស្រុកវ៉ារិន ខេត្តសៀមរាបនោះគឺជាទីដែលស្ថិតនៅសង្ខាងផ្លូវអាស៊ាន ។ គំរោងនៃការអភិវឌ្ឍន៍នេះដូចជាអភិវឌ្ឍន៍អគារខ្ពស់ៗជាខុនដូ វីឡ្សែត សណ្ឋាគារ កាស៊ីណូ និងមជ្ឍមណ្ឌល ដែលមានកំរិតស្តង់ដារអន្តរជាតិ ។

ក្រោយពី ធ្វើដំណើរកំសាន្តទៅតំបន់ទេសចរណ៍ នៅក្រុងព្រះសីហនុ និងខេត្តសៀមរាបរួចមក លោក*ជេម ស្ប៊ន* ឬតារាភាពយន្ត០០៧ បានសន្យាជាមួយលោកស្រី*កុល សុខុម* ថា លោកនឹងអំពាវនាវ ឬក៏ស្វែងរកដៃគូ អ្នកវិនិយោគទុនបរទេស ឱ្យមកបណ្តាក់ទុននៅស្រុកខ្មែរ និងពិសេសនោះ អ្វីដែលលោកបានផ្តិត ជារូបភាពក្នុងដំណើរទស្សនកិច្ចរយៈពេល២សប្តាហ៍នេះ ក៏នឹងធ្វើការចុះផ្សាយតាមទស្សនាវដ្តីល្បីៗនៅលើពិភពលោកដើម្បីទាក់ទាញការចាប់អារម្មណ៍ ដល់អ្នករកស៊ីធំៗនៅលើពិភពលោក ឱ្យមកបណ្តាក់ទុននៅកម្ពុជា ។

តារាភាពយន្ត០០៧ លោក*ជេម ស្ប៊ន* បានកោតសរសើរមិនដាច់ពីមាត់ ចំពោះស្រីខ្មែរ បើទោះបីជាស្ត្រីខ្លះ រៀនសូត្របានចេះដឹងទាបមែនប៉ុន្តែមានគំនិត និងកិរិតនៃការរកស៊ីខ្ពស់ គួរអោយកោតសរសើរក្នុងការរៀបចំខ្សែជីវិតរបស់ខ្លួន ។ ជាមួយគ្នានោះ លោក*ជេម ស្ប៊ន* ក៏បានសរសើរ លោកស្រ*កុល សុខុម* ថា ជាស្ត្រីខ្មែរគួរអោយកោតសរសើរ ចេះកែច្នៃប្រឌិតខ្សែជីវិត អោយក្លាយជាអ្នកជំនួញដ៏ធំ ជួយស្ត្រីខ្មែរ ទាំងផ្នែកគំនិត និងកម្លាំងចិត្ត ។

លោក*ជេម ស្ប៊ន* ក៏បានអះអាងប្រាប់លោកស្រី*កុលសុខុម* ថា លោកនឹងពាំនាំនូវអ្វី ដែលលោកបានឃើញការពិត នៅក្នុងប្រទេសកម្ពុជា អោយតារាភាពយន្តហូលីវូដជាច្រើនទៀត នៅលើពិភពលោកបានដឹង និងធ្វើយ៉ាងណា អោយពួកគេមកកម្ពុជាដូចលោក និងដើម្បីជួយអភិវឌ្ឍន៍ប្រទេសកម្ពុជា ឱ្យរីកចំរើន ។ តារាភាពយន្ត*ជេម ស្ប៊ន* ឬ០០៧ បានប្រាប់លោកស្រី*កុល សុខុម* ទៀតថាលោកជាតារាភាពយន្តពិភពលោក ។ ដូច្នេះមានការងារច្រើន ជាប់រវល់ណាស់, ប៉ុន្តែទោះជាយ៉ាងណាលោកនឹងវិលមកកម្ពុជានាពេលដ៏ឆាប់ៗខាងមុខនេះ ជាមួយនឹងប្រាក់ទុនសំរាប់ធ្វើការអភិវឌ្ឍន៍រួមគ្នា ជាមួយលោកស្រី*កុល សុខុម* ដែលជាស្ត្រីខ្មែរទាក់ទាញ ឱ្យមានការចាប់អារម្មណ៍ ពីតារាភាពយន្តពិភពលោករូបនេះ ។

លោកស្រី*កុលសុខុម* បានអំពាវនាវដល់ស្ត្រីខ្មែរគ្រប់រូបត្រូវតែរឹងប៉ឹង ក្លាហាន តាំងចិត្តជាស្ត្រីដ៏ល្អ ដល់ស្ត្រីគ្រប់រូប ក្នុងការរៀបចំខ្សែជីវិត អោយល្អប្រសើរ ។ លោកស្រីបានមានប្រសាសន៍ថា "*យើងជាស្ត្រីត្រូវធ្វើយ៉ាងណា ព្យាយាមធ្វើ ខ្លួនឱ្យបានល្អ ទាំងគំនិត និងទាំងបញ្ញា ដើម្បីទាក់ទាញដល់អ្នកវិនិយោគទុនពិភពលោក គេមកដាក់ទុនរកស៊ីនៅកម្ពុជា ។ ខ្ញុំសូមឱ្យស្ត្រីខ្មែរ បង្កើននូវចំណេះដឹង ដើម្បីឱ្យពិភពលោកមានការចាប់អារម្មណ៍, ហើយចំណែកខ្លួនខ្ញុំៗនឹងព្យាយាមជាបន្តទៀត ។ អ្វីគ្រប់យ៉ាង ខ្ញុំខំព្យាយាមគ្រប់យ៉ាង ដើម្បីប្រទេសជាតិយើង និងប្រជាពលរដ្ឋយើងសូម្បីត្រូវពលីអ្វីៗគ្រប់យ៉ាងក៏ខ្ញុំលះបង់ ដើម្បីកូនខ្មែរដែរ ។ ខ្ញុំចង់ធ្វើជាគំរូដល់ស្ត្រីខ្មែរ ដើម្បីឱ្យល្អ ធ្វើឱ្យកក្រើកដល់ពិភពលោក ទាំងការងារវិនិយោគ*" ។

មហាជនខ្មែរ បាននិយាយថា វត្តមានតារាភាពយន្ត*ជេម ស្ប៊ន* នៅកម្ពុជានេះ គឺជាការផ្តល់កិត្តិយស ដល់ប្រទេសខ្មែរសម្បើមណាស់ ជាពិសេសនៅពេលដែលលោក មកបំពេញទស្សនកិច្ចនៅកម្ពុជា នៅលើកក្រោយៗ គួរតែបើកចំហ ៕

---

**តមកពីទំព័រ៤ គ**

រំលោភបូរណភាពទឹកដីខ្មែរនេះ កាលពីចុងឆ្នាំ២០០៦ លោក *ហ៊ុន សែន* បានឆ្លលក្តៅងច្រមុះខ្លាំង នៅក្នុងកិច្ចប្រជុំប្រចាំសប្តាហ៍ របស់គណៈរដ្ឋមន្ត្រីរួចម្តងហើយ រហូតនិយាយ នៅក្នុងកិច្ចប្រជុំនោះថា នឹងបញ្ជូនកងទ័ព ប្រឈមមុខជាមួយនឹងទាហានឡាវទៀតផង ។ ប៉ុន្តែទម្លាប់ដែលខ្លាំងបានតែជាមួយខ្មែរនោះ, គេមិនឃើញលោក *ហ៊ុន សែន* បញ្ជាកងទ័ពអោយទៅប្រឈម ជាមួយទាហានឡាវទេ,ហើយភាពកំសាកនេះបានធ្វើឱ្យឡាវបានចិត្ត រហូតមានសេចក្តីរាយការណ៍ថា ទាហានឡាវ មិនទាន់អោយភាគីកម្ពុជា រំកិលប៉ុស្តិ៍ព្រំដែននៅជុំក្រឡ ទៅកន្លែងដើមវិញ នៅឡើយទេ ។

កាលពីថ្មីៗនេះ មន្ត្រីរដ្ឋាភិបាលបាននិយាយថា យួនបានរំកិលចូលព្រំដែនខ្មែរនៅចំណុចទី៧ នៃខេត្តមណ្ឌលគីរី ប្រវែង ៣០គីឡូម៉ែត្រ ។ តាំងពីពេលរំលោភរហូតមកដល់ពេលនេះ យួនបន្តត្រួតត្រា នៅលើទឹកដីខ្មែរដដែលគឺអត់ឃើញលោក *ហ៊ុន សែន* បញ្ជូនកងទ័ព ឱ្យទៅប្រឈមមុខគ្នាដូចគាត់បានធ្វើជាមួយសៀមនោះទេ ។

លោក*សម រង្ស៊ី* ប្រធានគណបក្សសម រង្ស៊ី បានប្រាប់អ្នកកាសែត មុនទៅបំពេញទស្សនកិច្ចនៅក្រៅប្រទេស កាលពីសប្តាហ៍មុនថារដ្ឋាភិបាលលោកស្រឡាញ់បូរណភាពទឹកដី កុំស្រឡាញ់តែខាងលិច គឺត្រូវតែស្រឡាញ់ខាងកើតដែរ ។ ការនិយាយដោយចំអក របស់ប្រធានគណបក្សប្រឆាំងនេះ នៅពេលលោក*ហ៊ុន សែន* ធ្វើដូចជាខ្នះខ្នែងរឿងព្រំដែន ជាមួយប្រទេសជិតខាងណាស់ តាមពិត លោក*ហ៊ុន សែន* ធ្វើជាបញ្ជូនទាហាន ទៅតតាំងជាមួយសៀមឈ្លានពាននោះ គឺដើម្បីចង់បានសន្លឹកឆ្នោត តែប៉ុណ្ណោះហើយក្រោយការបោះឆ្នោតគឺស្ងាត់លោក*ហ៊ុន សែន* មានវិធានការ ទប់ស្កាត់ការឈ្លានពាន របស់ប្រទេសជិតខាងឱ្យឃើង, ហើយព្វតែចោរសៀមឈ្លានពានចូលដីខ្មែរនៅកន្លែងនេះកន្លែងនោះជាហូរហែអត់ឈប់ឈរទាល់តែសោះ៕

---

**តមកពីទំព័រ២ ន**

ស្គាល់ថាជាប្រាសាទខ្មែរនោះផងដែរ នៅមុនទាហានសៀមដកឈ្លានពានរបស់ខ្លួនចេញពីទឹកដីខ្មែរនោះ។

បន្ទាប់ពីនោះក៏មានការព្រមជួបគ្នានៅថ្ងៃទី២៩ ខែសីហា នៅសៀមរាបប្រទេសកម្ពុជា។ គម្រោងនេះក៏ត្រូវបានលុបចោលទៅវិញ ដោយសៀមមិនបានពន្យល់ហេតុផលទេ ប៉ុន្តែគេគ្រាន់តែបានដឹងថា មានភាពជ្រួលច្របល់នយោបាយនៅទីក្រុងបាងកក និងរាលដាលពេញប្រទេសសៀមរហូតមកដល់សព្វថ្ងៃនេះ។

ប៉ុន្តែទាំងនេះរហូតមកដល់បច្ចុប្បន្នទើបគេបានដឹងថាជំហរនយោបាយការទូតនៃរដ្ឋាភិបាលគណបក្សប្រជាជន *ហ៊ុន សែន* វាចាញ់ប្រៀបសៀមដាច់ប៉ិត មិនថាឡើងវិស័យនយោបាយការពារជាតិ ដែល *ហ៊ុន សែន* ខ្លបខ្លាចសៀម រហូតដល់មិនហ៊ានទាំងឱ្យទាហានខ្មែរឃាត់ទាហានសៀមកុំឱ្យឆ្លងព្រំដែនចូលមកកាន់កាប់ដីខ្មែរនោះផងទេ។

បន្ទាប់ពីទាហានសៀមបានលើកគ្នាចូលកាន់វត្តកែវសិក្ខាគិរីស្វារៈលើទឹកដីខ្មែរ សៀមក៏បានអនុវត្តផែនការសង្គ្រាមចិត្តសាស្ត្រត្រជាក់បញ្ជូនទាហានមកកាន់កាប់ប្រាសាទតាមាន់ធំរបស់ខ្មែរ ក្នុងខេត្តបន្ទាយមានជ័យ។ ហើយជាហូរហែសៀមក៏បានបញ្ជូនទាហានរបស់ខ្លួនមកកាន់កាប់ទឹកដីខ្មែរនៅតំបន់នានាតាមបណ្តោយខ្សែព្រំដែនខ្មែរសៀមរហូតដល់អុកឡុកបំផ្លាញដំណាំខ្មែរនិងគំរាមកំហែងបំភិតបំភ័យប្រជារាស្ត្រខ្មែរ ។ល។

នៅពេលនេះរដ្ឋាភិបាលគណបក្សប្រជាជន *ហ៊ុន សែន* ដូចជាចាប់ដឹងខ្លួនខ្លះៗថា អំនួតរបស់ខ្លួនអំពីជំហរនៃការចរចាត្រឹមតែទ្វេភាគីផ្នែកការទូតរកដំណោះស្រាយបញ្ចប់ទំនាស់ព្រំដែនខ្មែរ-សៀម ក៏ក្លាយទៅជារឿងនៃការចាញ់បោកល្បិចនយោបាយការទូតរបស់សៀមស្រស់ៗពេក។ ដូច្នេះគេក៏បានឮ *ផៃ ស៊ីផាន* អ្នកនាំពាក្យនៃទីស្តីការគណៈរដ្ឋមន្ត្រី និយាយថា កម្ពុជាក៏ទុកឱកាសសម្រាប់ប្តឹងទៅក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិដែរ។

បើទោះជាយ៉ាងនេះក៏ដោយ រដ្ឋាភិបាលគណបក្សប្រជាជន *ហ៊ុន សែន* នៅតែប្រកាន់ជំហរថ្នមចិត្តសៀម ខ្លាចសៀមខឹង ហើយក៏នៅចាំមើលវិបត្តិនយោបាយនៅសៀមដោះស្រាយរួចពេលណា កែងសៀមអាចតែងតាំងរដ្ឋមន្ត្រីការបរទេសថ្មីឱ្យបើកការចរចាជាថ្មីជាមួយកម្ពុជា។ ក្នុងស្ថានភាពទន្ទឹងរង់ចាំមើលសៀមនេះរដ្ឋាភិបាលគណបក្សប្រជាជន *ហ៊ុន សែន* មិនហ៊ានលើកសំណុំរឿងនេះប្តឹងទៅក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិទេ បើទោះបីជាមានការជំរុញពីក្រុមអង្គការសង្គមស៊ីវិល និងប្រជាពលរដ្ឋក៏ដោយ៕

**សេវាទទួលទិញសម្ភារៈចាស់ៗ**
មានទទួលទិញ : ផ្ទះឈើ ផ្ទះថ្ម និងសំណង់អគារចាស់ៗតូច-ធំ គ្រប់ប្រភេទដែលត្រូវការរុះរើ ឬវាយចោល និង សម្ភារៈអេតចាយជាច្រើនមុខទៀតដូចជា : ដែក ស្ពាន់ អាលុយមីញ៉ូម ម៉ាស៊ីនត្រជាក់ ម៉ាស៊ីនភ្លើង អាគុយ ម៉ូទ័រ ។ល។
-មានសេវាចុះទិញតាមខេត្ត-ក្រុងទូទាំងប្រទេសកម្ពុជា
-មានទទួលទិញក្នុងតម្លៃសមរម្យ
-ចំពោះអ្នកដែលផ្តល់ព័ត៌មានក្នុងការទិញលក់នេះ ក្រុមហ៊ុននឹងផ្តល់កម្រៃជើងសារបន្ថែម
ទំនាក់ទំនងទូរស័ព្ទលេខ : **017 606 125**

**ក្រុមហ៊ុនភាពយន្ត ជនបទ**
**មានទទួលបញ្ចាំង ខ្សែភាពយន្តខ្នាតធំ ក្នុងពិធីផ្សេងៗ មានពន្លឺច្បាស់ ទំនាក់ទំនងតាមទូរស័ព្ទ**
**012 66 44 67**
**015 66 44 67**

**ខ្មែរម្ចាស់ស្រុក**
Khmer Machas Srok News
ការិយាល័យនិពន្ធ
Tel : 012 969 832 , 012 850 690
Fax : 023 987 411
E-mail: kmsnews@gmail.com
www.kmsblog.wordpress.com
ផ្នែកផ្សាយពាណិជ្ជកម្ម
Tel: 012 850 690 , 017 360 678, 015 645 170

**តមកពីទំព័រ១ ម**

បក្សសិទ្ធិមនុស្ស ដែលឈ្នះបានអាសនៈសរុប ចំនួន២៩នៅក្នុងរដ្ឋសភានោះ បានប្រកាសជាថ្មីម្តងទៀតពីទ្វីបអឺរ៉ុបមកថានឹងមិនចូលរួមប្រជុំ និងស្បថចូលកាន់តំណែង នៅថ្ងៃដំបូងនេះទេ ។

ព្រះរាជសារកោះប្រជុំរបស់ព្រះមហាក្សត្រ ចំនួន២៦ច្បាប់ សំរាប់អ្នកតំណាងរាស្ត្រ គណបក្សសម រង្ស៊ីទាំង២៦រូបដែលមន្ត្រីព្រះបរមរាជវាំង បានយកទៅដល់ទីស្នាក់ការកណ្តាល នៃគណបក្សសម រង្ស៊ី ក្រុងភ្នំពេញ នៅព្រឹកម្សិលមិញនេះ គឺព្រះអង្គបានកោះហៅ អ្នកតំណាងរាស្ត្រគណបក្សសម រង្ស៊ី តាំងពីថ្ងៃទី៨ កញ្ញា ២០០៨ ។

នៅថ្ងៃទី៨ កញ្ញា ២០០៨ នោះដែរ លោក*គុយ សុផល* រដ្ឋលេខាធិការ នៃក្រសួងព្រះបរមរាជវាំង ក៏បានអមលិខិតមួយ ជូនដល់អគ្គលេខាធិការគណបក្សសម រង្ស៊ី ដោយមាននៅក្នុងកម្មវត្ថុ យ៉ាងដូច្នេះថា "*សូមប្រគល់ជូន ព្រះរាជសារកោះប្រជុំ ចំនួន២៦ច្បាប់* " ។

ព្រះរាជសារ កោះប្រជុំនៅថ្ងៃទី២៤ កញ្ញា ២០០៨នោះគឺទ្រង់យល់សេចក្តីសំរេច លេខ ៦០៤/០៨ គ.ជ.ប ចុះថ្ងៃទី២ ខែកញ្ញា ២០០៨ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតស្តីពីការប្រកាសលទ្ធផលផ្លូវការ នៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ អាណត្តិទី៤ ថ្ងៃអាទិត្យ ទី២៧ ខែកក្កដា ឆ្នាំ២០០៨ ។ ប៉ុន្តែសេចក្តីសំរេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតនេះ មិនត្រូវបាន គណបក្សប្រឆាំងធំៗ ចំនួន២ គឺគណបក្សសម រង្ស៊ី និងគណបក្សសិទ្ធិមនុស្សទទួលស្គាល់ទេ ហើយបាននាំយកនូវឯកសារ ភស្តុតាង នៃភាពមិនប្រក្រតី បង្ហាញសហគមន៍អឺរ៉ុប និងអង្គការសហប្រជាជាតិអោយដឹងឮ អំពីភាពមិនប្រក្រតី នៃការបោះឆ្នោតនេះទៀតផង ។

លោក*សម រង្ស៊ី* បានមានប្រសាសន៍ច្រើនដងហើយថា អ្នកតំណាងរាស្ត្រ នៃគណបក្សសម រង្ស៊ី ទាំង២៦រូប មិនអាចចូលរួមស្បថជាមួយសមាជិកសភាគណបក្សប្រជាជន ទាំង៩០រូប ដែលខ្លះបានមកដោយសារអ្នកគ្មានសិទ្ធិបោះឆ្នោត ប្រើឈ្មោះខ្មោចបោះឆ្នោត, ជនជាតិយួនបោះឆ្នោតអោយ ។ លោក*សម រង្ស៊ី* បានបញ្ជាក់ទៀតថា អ្នកតំណាងរាស្ត្រ គណបក្សប្រជាជន មិនមែនតំណាងឱ្យរាស្ត្រខ្មែរទេ តំណាងឱ្យខ្មោចតំណាងឱ្យចោរ និងតំណាងឱ្យយួន ។

ទោះយ៉ាងណា អ្នកវិភាគនិយាយថា លោក*ហ៊ុន សែន* នៃគណបក្សប្រជាជន នឹងប្រើព្រះនាមព្រះមហាក្សត្រ ដើម្បីគាបសង្កត់ អ្នកតំណាងរាស្ត្រគណបក្សសម រង្ស៊ី និងគណបក្សសិទ្ធិមនុស្ស អោយចូលរួមប្រជុំសភា នៅថ្ងៃដំបូង ដែលគ្រោងនឹងធ្វើ នៅថ្ងៃទី២៤ ខែកញ្ញា ២០០៨ ។

អ្នកវិភាគដដែល បានបន្តថា កាលពីឆ្នាំ២០០៥ លោក*ហ៊ុន សែន*បានគំរាមព្រះមហាក្សត្រ អោយឡាយ ព្រះហស្ថលេខាលើសន្ធិសញ្ញាបំពេញបន្ថែម ឆ្នាំ១៩៨៥ហើយដែលកាលណោះ គេចាំសម្តីលោក*ហ៊ុន សែន* ព្រមានព្រះមហាក្សត្រ ជាចំហថា បើសិនជា ព្រះមហាក្សត្រមិនឡាយព្រះហស្ថលេខាទេ នឹងផ្លាស់ប្តូររបបនៅកម្ពុជា ពីរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញទៅជារបបសាធារណរដ្ឋវិញ ។

ដូច្នេះសម្តីលោក*ហ៊ុន សែន* នេះ ត្រូវបានគេយល់ថា គឺជាការគាបសង្កត់ ដល់ព្រះមហាក្សត្រ ឱ្យឡាយព្រះហស្ថលេខាលើសន្ធិសញ្ញាបំពេញបន្ថែមឆ្នាំ១៩៨៥ដែរ ។ ដូចគ្នានេះដែរគេសង្ស័យថា លោក*ហ៊ុន សែន* នឹងប្រើប្រាស់ ព្រះមហាក្សត្រ ដើម្បីដាក់សម្ពាធ ទៅលើអ្នកតំណាងរាស្ត្រ គណបក្សសម រង្ស៊ី ឱ្យចូលរួមប្រជុំសភា នៅថ្ងៃដំបូងដែរ ដើម្បីឱ្យស្របទៅតាមមាត្រា៧៦ នៃរដ្ឋធម្មនុញ្ញ ដែលតម្រូវឱ្យ មានសមាជិកសភាថ្មីប្រជុំនៅថ្ងៃដំបូង យ៉ាងតិច១២០រូប នៃសមាជិកសភាសរុបចំនួន១២៣រូប ។

អ្នកច្បាប់មួយរូបបានឱ្យដឹងថាទំនងជាមានការសំរបសំរួលតាមច្រកណាមួយ រវាងគណបក្សកាន់អំណាចនិងគណបក្សប្រឆាំងនៅប្រទេសកម្ពុជា នៅថ្ងៃប្រជុំសភាដំបូងនេះពិសេសបន្ទាប់ពីមានវត្តមាន របស់អ្នកមានឥទ្ធិពលម្នាក់នៃក្រសួងការបរទេសអាមេរិក មកបំពេញទស្សនកិច្ចនៅកម្ពុជា នៅពាក់កណ្តាលខែកញ្ញានេះ ។

លោក*ហ៊ុន សែន* ធ្លាប់ព្រមានលោក*សម រង្ស៊ី* និងសមាជិកសភាថ្មី គណបក្សសម រង្ស៊ី ទាំង២៦រូបថា បើមិនព្រមចូលរួមប្រជុំនៅថ្ងៃដំបូងទេ គាត់នឹងយកកៅអីនោះ ទៅចែកគ្នាជាមួយគណបក្សផ្សេង ។ ប៉ុន្តែលោក*អ៊ឹម សួស្តី* ប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានចេញលិខិត នៅថ្ងៃទី០២ កញ្ញា ២០០៨ ប្រកាសទទួលស្គាល់ អ្នកតំណាងរាស្ត្រគណបក្សសម រង្ស៊ីថ្មី ទាំង២៦រូបហើយ ។ សេចក្តីសម្រេចរបស់លោក*អ៊ឹម សួស្តី* ត្រង់ប្រការមួយបានចែងថា "*ប្រកាសទទួលស្គាល់ជាផ្លូវការ បេក្ខជនជាប់ឆ្នោតជាតំណាងរាស្ត្ររបស់គណបក្សសម រង្ស៊ី ដូចមាននៅក្នុងតារាងខាងក្រោមតាមមណ្ឌល ខេត្ត ក្រុងនីមួយៗក្នុងការបោះឆ្នោត ជ្រើសរើសតំណាងរាស្ត្រអាណត្តិទី៤ នៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៨*" ។ ឈ្មោះ អ្នកតំណាងរាស្ត្រគណបក្សសម រង្ស៊ីទាំងនោះ គឺនៅមណ្ឌលបន្ទាយមានជ័យ ចំនួនម្នាក់លោក*យន្ត ថារូ*, មណ្ឌលបាត់ដំបងចំនួន២នាក់ គឺលោក*អេង ឆៃអ៊ាង* និងលោក *ជីវ កត្តា*,មណ្ឌលកំពង់ចាម ចំនួន៥រូបគឺលោក *សម រង្ស៊ី*, លោក*ម៉ៅ មុនីវណ្ណ*,លោក*ជាម ច័ន្ទនី*, លោកស្រី*ថាក់ ឡានី*និងលោក*គឹមសួរ ភិរិទ្ធ*, មណ្ឌលកំពង់ឆ្នាំងម្នាក់គឺលោក*យី វណ្ណដេត*, មណ្ឌលកំពង់ស្ពឺម្នាក់ គឺលោក*នុត រំដួល*, មណ្ឌលកំពង់ធំម្នាក់លោក*ម៉ែន សុថាវរិន្ទ្រ*,មណ្ឌលកំពតម្នាក់គឺលោកស្រី*មូរ សុខហួរ*, មណ្ឌលកណ្តាល៣រូបគឺលោក*ចាន់ ចេង*, លោក*យ៉ឹម ឡាគី* និង លោកស្រី*ពត ពៅ*, មណ្ឌលក្រចេះម្នាក់ គឺលោក*ឡុង រី*, មណ្ឌលភ្នំពេញ៥រូបគឺលោកស្រី*ជូឡុង សូមូរ៉ា*,លោក*យ៉ឹម សុវណ្ណ*, លោក*សុន ឆ័យ*, លោក*ហូរ វ៉ាន់* និងលោក ស្រី*លី ស្រីវីណា*, មណ្ឌលព្រៃវែង ២រូបគឺលោក*ជា ប៉ូច*និងលោក*គង់ បូរ៉ា*, មណ្ឌលសៀមរាបម្នាក់គឺលោកស្រី*កែ សុវណ្ណរតន៍* និងមណ្ឌលតាកែវ២រូបគឺលោក*គួយ ប៊ុនរឿន*និងលោក*តុ វ៉ាន់ចាន់* ។

គួររំលឹកថា មុននេះបន្តិចលោក*សម រង្ស៊ី* ប្រធានគណបក្សសមរង្ស៊ីបានស្នើសុំទៅព្រះមហាក្សត្រ ដើម្បីធ្វើពិធីសច្ចាប្រណិធានចូលកាន់តំណែងនៅថ្ងៃទី២៥ កញ្ញា ២០០៨ដាច់ដោយឡែក ពីសមាជិកសភាមកពីគណបក្សប្រជាជន ៕

**តមកពីទំព័រ១ គ**

គគីរខាងកើតជាដើម ។ ការបន្តឈ្លានពានយ៉ាងខ្លាំងក្លានិងមិនឈប់ឈរនេះនៅពេលដែលពួកចោរសៀមបានដឹងថាគណបក្សប្រជាជនលោក*ហ៊ុន សែន* លួចបន្លំឆន្ទៈ ប្រជាពលរដ្ឋខ្មែរទទួលបាន៩០កៅអីនៃរដ្ឋសភាខ្មែរ ដែលមានកៅអីសរុបចំនួន ១២៣ ។

ក្រៅពីចោរសៀម ឈ្លានពានបូរណភាពទឹកដីខ្មែរ ចោរសៀមទាំងនោះបានមើលងាយខ្មែរខ្លាំងណាស់ ដូចជាបោះត្រានៅលើខ្លួនប្រាណ ប្រជាពលរដ្ឋខ្មែរណា ដែលចង់ចូលទស្សនាប្រាសាទតាមាន់ធំរបស់ខ្មែរ ។ ចោរសៀមឈ្លានពាន ក៏បានគំរាមប្រជាពលរដ្ឋ ឱ្យរុះរើលំនៅដ្ឋាន នៅភូមិជប់គគីរខាងកើតក្នុងទឹកដីខ្មែរ នៃខេត្តឧត្តរមានជ័យទៀតផង ។ ថ្មីៗនេះមានសេចក្តីរាយការណ៍ ដោយកាសែតក្នុងស្រុកថា សមត្ថកិច្ចសៀមបានឱ្យឆ្កែហិតប្រជាពលរដ្ឋខ្មែរតាំងពីចុងជើងរហូតដល់ក្បាលនៅច្រកចាំយាម ខេត្តកោះកុង។ ស្ថិតនៅក្នុងសភាពដែលចោរសៀមមើលងាយខ្មែរដល់កំរិតនេះទៅហើយនាយករដ្ឋមន្ត្រី*ហ៊ុន សែន* បានត្រឹមតែនិយាយថាអត់ធ្មត់ ។ ប៉ុន្តែបើសិនជាមួយខ្មែរគ្នាឯងវិញ ចាំមើលលោក*ហ៊ុន សែន* ខ្លាំងគឺខ្លាំង រហូតដល់មានពេលខ្លះគាត់បាននិយាយ លែងដឹងខុសត្រូវទៀតផង ។

ស្របពេលដែលចោរសៀមទន្រ្ទានបូរណភាពទឹកដីខ្មែរ ជាច្រើនកន្លែង នៅតំបន់ព្រំដែនភាគខាងលិចនោះមានព័ត៌មានពីភាគឦសានថា ឡាវដែលជាប្រទេសមួយតូចច្រមក់នៅក្នុងឥណ្ឌូចិននោះ ក៏មានមហិច្ឆតាលោភលន់រំកិលព្រំដែនចូលក្នុងដីខ្មែរយ៉ាងងងើលដែរ ពិសេសនៅម្តុំច្រកដុំក្រឡ ក្នុងទឹកដីនៃខេត្តស្ទឹងត្រែង ។

លោក*ម៉ៅ មុនីវណ្ណ* សមាជិកសភា គណបក្សសម រង្ស៊ី ដែលបានចុះទៅពិនិត្យ ព្រំដែនដោយផ្ទាល់ កាលពីខែសីហា ឆ្នាំ២០០៨ បានប្រាប់*ខ្មែរម្ចាស់ស្រុក* កាលពីថ្ងៃអាទិត្យកន្លងទៅនេះថា ប៉ុស្តិ៍ព្រំដែនខ្មែរនៅដុំក្រឡ ត្រូវទាហានឡាវបញ្ជាឱ្យដកថយក្រោយ ចូលក្នុងទឹកដីខ្មែរ ប្រមាណ៤គ.ម, ហើយភាគីឡាវ បានហាមមិនអោយភាគីកម្ពុជា ធ្វើផ្លូវនៅលើដីខ្លួនឯងផងដែរ។ ប៉ុន្តែក្រោយមកឡាវ បានអនុញ្ញាតឱ្យធ្វើវិញ, ហើយប៉ុស្តិ៍ព្រំដែននោះ គឺរក្សាទុក នៅក្នុងដីខ្មែរចម្ងាយ ៤ គ.មដដែល ។

លោក*ម៉ៅ មុនីវណ្ណ* ដែលបានចុះទៅដល់ព្រំដែន ភាគឦសានប្រទេសនិងភាគខាងកើតនោះ បានឮប្រជាពលរដ្ឋត្អូញត្អែរផ្ទាល់ត្រចៀក និងមានប្រជាពលរដ្ឋខ្លះ បានរិះគន់លោក*ហ៊ុន សែន* ថា បើសិនជាមានអ្នកស្នេហាជាតិជាពិសេសសមាជិកសភា គណបក្សសម រង្ស៊ី, ក្រុមឃ្លាំមើលកម្ពុជា អង្គការក្រៅរដ្ឋាភិបាល ក៏ដូចជាអ្នកដែលមានជំនាញព្រំដែន រិះគន់ឬនិយាយ អំពីការចង់បានទឹកដីខ្មែរដែលបាត់បង់ ដោយយួនរំលោភយកនោះ បែរជាលោក*ហ៊ុន សែន* ព្រមានធ្វើក្តារម្សៀឱ្យ។ ប៉ុន្តែនៅពេលចោរសៀមឈ្លានពាន បែរជាលោក*ហ៊ុន សែន* ធ្វើជាបញ្ជូនកងទ័ព ធ្វើដូចគាត់ ស្រឡាញ់ទឹកដីខ្មែរសម្បើមណាស់ ។ តាមពិតគឺលោក*ហ៊ុន សែន* មិនខ្វាចនឹងការបាត់បង់ បូរណភាពទឹកដីអ្វីទេ គឺបុរសនេះបារម្ភតែរបូតអំណាចពីដៃប៉ុណ្ណោះ ។ ដូច្នេះហើយ បានជាគាត់ហ៊ានធ្វើអ្វីៗគ្រប់យ៉ាង ឱ្យតែលួចប្លន់ឆន្ទៈប្រជាពលរដ្ឋបានក្រោមរូបភាពការបោះឆ្នោត ។

ពាក់ព័ន្ធ ទៅនឹងឡាវហ៊ាន

**តនៅទំព័រ៣ គ**

**តមកពីទំព័រ១ ក**

**ទំនិញឡើងថ្លៃ ចាប់ផ្តើមដោយប្រេងសាំងឡើងថ្លៃឥតឈប់ បើទោះបីជាប្រេងនៅលើទីផ្សារអន្តរជាតិចាប់ផ្តើមធ្លាក់ចុះក៏ដោយនោះ។ កង្វល់របស់ប្រជារាស្ត្រនៅតែសម្តែងឱ្យឃើញអំពីការមិនមានជំនឿទំនុកចិត្តលើគណបក្សប្រជាជន ហ៊ុន សែន ដែលបើទោះបីជាគណបក្សនេះចេះប្រើល្បិចតាមរយៈ គ.ជ.ប ជាឧបករណ៍របស់ខ្លួន និងអាជ្ញាធរដែនដីជាដៃជើងរបស់ខ្លួនលួចបន្លំប្លន់យកសន្លឹកឆ្នោតប្រជារាស្ត្រ និងបំភ្លែលទ្ធផលឆ្នោតឱ្យខ្លួនឃើញបានអាសនៈសភាដល់ទៅ៩០ដើម្បីឱ្យខ្លួនបានកាន់អំណាចផ្តាច់មុខនោះ។**

**ជាមួយលទ្ធផលដែលធ្វើឱ្យប្រជារាស្ត្រម្ចាស់សន្លឹកឆ្នោតសម្តែងការក្តៅក្រហាយនៅពាសពេញប្រទេស ហើយដែលមានការថ្កោលទោសដល់របៀបរបបគ្រប់គ្រងប្រទេសរបស់គណបក្សប្រជាជន ហ៊ុន សែន នេះ ក្រុមហ៊ុនសែនកំពុងដេកស្រមៃថា នៅថ្ងៃទី២៤ ខែកញ្ញា ពួកខ្លួននឹងបានចូលទៅស្បថក្នុងសភា ដើម្បីឱ្យបានក្លាយទៅជាការមានសភាជាតិថ្មី ហើយជាមួយគ្នានោះ ហ៊ុន សែន ក៏ដេកយល់សព្វថា ខ្លួននឹងបានជាប់ឆ្នោត ក្នុងការបោះឆ្នោតកញ្ចប់បែបការគាបសង្កត់គណបក្សប្រជាជនខ្លួនឯងឱ្យធ្វើយ៉ាងនេះ។ គឺការស្រមៃអំពីមហិច្ឆតាអំណាចគ្មានព្រំដែនរបស់ ហ៊ុន សែន ដូចដែលគាត់នេះបាននិយាយអួតអាងចង់ធ្វើនាយករដ្ឋមន្ត្រីអស់មួយជីវិតដោយមិនគិតខ្វល់ពីបញ្ហាសុខទុក្ខរបស់ប្រទេស និងរបស់ប្រជារាស្ត្រនោះ។**

**ក្នុងផ្ទៃរបស់គណបក្សប្រជាជន គេអាចយល់បានតាមរយៈការថ្លែងរបស់អ្នកនាំពាក្យគណបក្សប្រជាជនលោក ខៀវ កាញារីទ្ធ កាលពីពេលកន្លងទៅថា នឹងមានការបោះឆ្នោតកញ្ចប់សម្រេចលើការជ្រើសតាំងលោក ហ៊ុន សែន ឱ្យធ្វើជានាយករដ្ឋមន្ត្រីដំណាលគ្នានឹងការបោះឆ្នោតកញ្ចប់ជ្រើសតាំងប្រធានម្នាក់ និងអនុប្រធានពីរនាក់នៃសភាជាតិ។ ការនិយាយបែបនេះបង្ហាញឱ្យគេដឹងថា គណបក្សប្រជាជនជាពិសេស ហ៊ុន សែន មានការខ្វល់ខ្វាយអំពីកម្លាំងប្រតិកម្មផ្ទៃក្នុងគណបក្សប្រជាជនខ្លួនឯង រួចក៏បង្ខំឱ្យមានការបោះឆ្នោតជាកញ្ចប់បែបនេះ ដើម្បីធានាថា ខ្លួនក៏នឹងបានធ្វើជានាយករដ្ឋមន្ត្រី បើទោះជាការធ្វើបែបនេះជាការខុសឆ្គងរំលោភបំពានរដ្ឋធម្មនុញ្ញរបស់ប្រទេសនោះ។**

**បណ្ឌិត ឡៅ ម៉ុងហៃ ជាអ្នកសិក្សាស្រាវជ្រាវជាន់ខ្ពស់នៃគណៈកម្មាធិការសិទ្ធិមនុស្សអាស៊ី ដែលមានមូលដ្ឋាននៅទីក្រុងហុងកុង និងជាអ្នកសង្កេតការណ៍ជើងចាស់បានអត្ថាធិប្បាយថា ស្ថានការណ៍របស់ប្រទេសកម្ពុជាបច្ចុប្បន្ន ពុំតម្រូវឱ្យមានការបោះឆ្នោតកញ្ចប់ដោយប្រើរដ្ឋធម្មនុញ្ញបន្ថែមនោះទេ។ ហើយការធ្វើបែបនេះ ក៏ជាការធ្វើឱ្យគេកាត់យល់បានថា ក្នុងផ្ទៃគណបក្សប្រជាជនកំពុងមានការមិនជឿទុកចិត្តគ្នាពោលគឺមានបញ្ហានៃការប្រជែងអំណាចរវាងគ្នា។**

**យ៉ាងណាក៏ដោយ សម្រាប់ប្រជារាស្ត្រ អំណាចរបស់ ហ៊ុន សែន កុំថាឡើយដល់ទៅមួយជីវិតរបស់ ហ៊ុន សែន សូម្បីតែកន្លះជីវិត ឬមួយថ្ងៃក៏មិនមែនជាទីប្រាថ្នាចង់បានសប្បាយអបអររបស់ប្រជារាស្ត្រនោះទេ។ នេះពីព្រោះគេដឹងជាទូទៅថា ដោយអំណាចរបស់ ហ៊ុន សែន យ៉ាងច្របូកច្របល់អនាធិបតេយ្យ ទើបបានជាមានការកាប់បំផ្លាញធនធានរបស់ប្រទេសដូចជាព្រៃឈើ ក៏ដូចជាការលក់ដីធ្លីសម្បត្តិរដ្ឋអស់ស្ទើរតែពាក់កណ្តាលទៅឱ្យឈ្មួញ។ ហើយតំណាលគ្នានោះ ជីវភាពរបស់ប្រជារាស្ត្រក៏នៅតែបន្តរងគ្រោះវេទនាតោកយ៉ាកជាមួយការបាត់បង់ដីធ្លីជាមូលដ្ឋាននៃជីវិតកសិករដែលមានកសិករចំនួន៨០ភាគរយរស់នៅតាមតំបន់ជនបទពឹងលើដីធ្លីនោះ។**

**ប៉ុន្តែបើពិនិត្យឱ្យជ្រៅវែងឆ្ងាយទៅ អ្វីដែលជាកង្វល់ប្រចាំថ្ងៃរបស់ប្រជារាស្ត្រនោះ គឺបញ្ហាជីវភាពដែលប្រឈមមុខនឹងបញ្ហាទំនិញឡើងថ្លៃដែលនៅតែពុំព្រមចុះ ដូច្នេះធ្វើឱ្យបន្ទុកនៃជីវភាពក្រីក្រ របស់ប្រជារាស្ត្រកាន់តែវេទនា តំណាលគ្នានឹងអ្នកមាន អ្នកធំ មួយក្រុមតូចក៏នាំគ្នាឆក់ប្លន់ទ្រព្យសម្បត្តិធនធានរបស់ប្រទេស បង្កើនគំនរទ្រព្យរបស់ខ្លួនក្លាយទៅជាសេដ្ឋីលើភាពក្រីក្រ របស់ប្រទេស និងប្រជារាស្ត្រឯងនោះ។**

**គេអាចមើលឃើញ និងដឹងថា រដ្ឋាភិបាលគណបក្សប្រជាជន ហ៊ុន សែន គ្មានឆន្ទៈចេតនានឹងដោះស្រាយបញ្ហាជីវភាពលំបាករបស់ប្រជារាស្ត្រនោះនៅត្រង់ថា បើទោះបីជាប្រេងនៅលើទីផ្សារអន្តរជាតិមានតម្លៃធ្លាក់មកដល់ត្រឹម១០២ ដុល្លារក្នុងមួយបារ៉ែលក៏ដោយ ក៏ប្រេងសាំងនៅលើទីផ្សារកម្ពុជានៅតែមានតម្លៃខ្ពស់ដដែល។ នេះជាភស្តុតាងបង្ហាញប្រាប់ប្រជារាស្ត្រថា ដរាបណាគណបក្សប្រជាជន ជាពិសេស ហ៊ុន សែន នៅតែកាន់អំណាចនៅកម្ពុជា នោះច្បាស់ណាស់ថា ជីវភាពរបស់ប្រជារាស្ត្រខ្មែរមិនអាចធូរធារឡើយ បើទោះបីជាមានការអួតក្អេងក្អាងរបស់ ហ៊ុន សែន អំពីការដឹកនាំរដ្ឋាភិបាលឱ្យមានកំណើនសេដ្ឋកិច្ចដល់២ខ្ទង់ក៏ដោយនោះ។**

**ការលូតលាស់សេដ្ឋកិច្ចដល់១០ភាគរយ ក៏ត្រូវពួកអ្នកសង្កេតការណ៍ ជាពិសេសមន្ត្រីជំនាញសេដ្ឋកិច្ច ទាំងអង្គការសេដ្ឋកិច្ចអន្តរជាតិពិពណ៌នាថា មិនជួយអ្វីដល់ប្រជារាស្ត្រខ្មែរក្រីក្រនោះទេ ពីព្រោះតែទំនិញឡើងថ្លៃក្នុងកម្រិតដល់ទៅជាង២ដងនៃការលូតលាស់សេដ្ឋកិច្ចនោះ។ហើយអ្វីដែលហៅថាជាការលូតលាស់សេដ្ឋកិច្ចនៅក្រោមការត្រួតត្រារបស់រដ្ឋាភិបាលគណបក្សប្រជាជន ហ៊ុន សែន នោះ បើគិតឱ្យមែនទែនទៅវាពុំមែនជាការលូតលាស់សេដ្ឋកិច្ចក្នុងសុខភាពសេដ្ឋកិច្ចមាំទាំនោះទេ ប៉ុន្តែគឺជាការបង្កើតបញ្ហានៅត្រង់នេះធ្វើឱ្យមានកំណើនដូចផ្សែកសំណង់សម្រាប់បង្ហាញរាងបំភាន់ប្រជារាស្ត្រ ដោយខាងសំណង់ខ្លួនឯងកំពុងមានបញ្ហាពីព្រោះតម្លៃសំណង់ខ្ពស់ពេក ពុំអាចមានអ្នកទិញបាន ដូច្នេះក៏ឃើញមានសំណង់ខ្លះនៅអេ ហើយបញ្ហានៃការលូតលាស់ខាងសំណង់ក៏នៅទ្រឹង ដូចវិបត្តិដែលមាននៅប្រទេសសៀម និងប្រទេសនានាអញ្ចឹងដែរ។ ប៉ុន្តែនេះក៏ជាល្បិចបញ្ឆោតមួយរបស់គណបក្សប្រជាជន ហ៊ុន សែន ដើម្បីអ្វីដែលថា វាអាចជាយុទ្ធនាការ នៃការលាងលុយកង្វក់របស់ពួកអ្នកធំ និងអ្នកមានអំណាចរកស៊ីជាមួយឈ្មួញទុច្ចរិតនោះ។ ទាំងអស់នេះពុំមែនជាចំណាប់អារម្មណ៍របស់ប្រជារាស្ត្រខ្មែរនោះទេ តែជាកង្វល់របស់ប្រជារាស្ត្រខ្មែរទៅវិញ ពីព្រោះប្រេងសាំងនៅតែឡើងថ្លៃ ទំនិញសព្វសារពើនៅតែមានតម្លៃខ្ពស់ ប្រាក់ខែក៏នៅតែមានកម្រិតទាប អំពើពុករលួយក៏នៅតែលូតលាស់ខ្លាំង ទាំងរដ្ឋាភិបាលគណបក្សប្រជាជនពុំមានផែនការនយោបាយអ្វីច្បាស់លាស់នឹងដោះស្រាយបញ្ហាអស់ទាំងនេះឱ្យប្រទេសជាតិ និងប្រជារាស្ត្រនោះឡើយ៕**